**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តសៀមរាប**

**គណៈកម្មាធិការលទ្ធកម្ម**

លេខៈ...១១៦/០១៨......រសស.សជណ

# សេចក្តីជូនដំណឹង (លើកទី២)

## ស្តីពី

ការអញ្ជើញចូលរួមពិគ្រោះថ្លៃការផ្គត់ផ្គង់បរិក្ខារអគ្គិសនី និងមេកានិច

រដ្ឋាករទឹកស្វយ័តសៀមរាប សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តសៀមរាប នឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់បរិក្ខារអគ្គិសនី និងមេកានិច។

រដ្ឋាករទឹកស្វយ័តសៀមរាប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តសៀមរាប ដែលមានអាសយដ្ឋានស្ថិតនៅទីតាំងខាងកើតស្ពានថ្មព្រះរាជដំណាក់ ជាប់ផ្លូវជាតិលេខ៦ ភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៦៣ ៩៦៣ ០២៥)។

កាលបរិច្ឆេទឈប់ទទួលសំណើពិគ្រោះថ្លៃ នៅម៉ោង **១០ម៉៣០នាទីព្រឹក ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨** ។

ការបើកសំណើពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង **១០ម៉៣០នាទីព្រឹក ថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៨** នៅរដ្ឋាករទឹកស្វយ័តសៀមរាប តាមអាសយដ្ឋានខាងលើ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ.ចន្ទ ៨ កើត.........ខែ..ពិសាខ....ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦១

ធ្វើនៅសៀមរាប,ថ្ងៃទី.២៣.....ខែ.មេសា...ឆ្នាំ ២០១៨

**ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធានទី១**

**ចាន់_សេខឡុះ**

ចម្លងជូនៈ

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ